# ១-លំនាំដើម

តាមប្រពៃណីខ្មែរយើង បុណ្យទាំងឡាយអាចចែកជាពីរពួក គឺ:

បុណ្យផ្នែកពុទ្ធសាសនា ដូចជាបុណ្យ មាឃបូជា វិសាខបូជា កឋិន ជាដើម និង បុណ្យផ្នែកប្រពៃណីដូចជា ចូលឆ្នាំ ឬ ភ្ជុំបិណ្ឌ។

បុណ្យនីមួយៗ ច្រើនចាប់ផ្តើម ពីម៉ោង១០ ព្រឹករហូតដល់ម៉ោង ១១ព្រឹក(១) ដោយមានលោកអាចារ្យជាអ្នកណែនាំតាមកម្មវិធីរបស់អ្នកដើមបុណ្យ។

លោកអាចារ្យបន្ទាប់ពីរៀបចំផ្កាភ្ញីសមរម្យ និង អុជទៀនធូបនៅចំពោះព្រះភក្ត្រ ព្រះពុទ្ធរូបហើយ ក៏អញ្ជើញពុទ្ធបរិស័ទព្រមទាំងញាតិមិត្តអ្នកដើមបុណ្យ ឲ្យតាំងសតិស្មារតី ហើយណែនាំ ចាប់ផ្តើមពិធី តាមលំដាប់ ដូចតទៅនេះ ៖

១-នមស្សការព្រះរតនត្រ័យ

២-សមាទានសីល (មានសីល៥ជាដើម)

៣-និមន្តព្រះសង្ឃចំរើនព្រះបរិត្ត

៤-ពុទ្ធបរិស័ទ នាំគ្នារាប់បាត្រ, (២)

---

(១)-អ្នកខ្លះគេនិមន្តព្រះសង្ឃចំរើនបរិត្តពីល្ងាច ព្រឹកឡើងរាប់បាត្រ ។

(២)- អ្នកខ្លះគេរាប់បាត្រ បើមិនរាប់បាត្រ គេអាចលើកចង្ហាន់មកវេរតែម្តងក៏បាន ។

<u>ក្នុងការរាប់បាត្រ តើត្រូវរាប់ពីណាទៅមុន ?</u>

មុននឹងឆ្លើយ ខ្ញុំសូមលើកយកការរៀបចំដូចតទៅនេះ :

-ក្នុងពិធីរៀបកន្លែងព្រះសង្ឃ តាមធម្មតាព្រះពុទ្ធរូប គេ តម្កល់នៅខាងស្តាំដៃព្រះសង្ឃ ប៉ុន្តែបើមិនអាចតម្កល់ខាងស្តាំបាន ត្រូវលៃលក រកកន្លែងតម្កល់ តាមសមគួរ។

៥-លោកអាចារ្យនាំពុទ្ធបរិស័ទវេរកត្តប្រគេនព្រះសង្ឃហើយពុទ្ធបរិស័ទថាតាមអាចារ្យ,

៦-ប្រគេន ចង្ហាន់បិណ្ឌបាត និង ទេយ្យទាន ដល់ព្រះសង្ឃ,

---

-ក្នុងការរៀបបាត្រ :

ទី១ : ផ្តិលតង្វាយព្រះ

ទី២ : បាត្រព្រះសង្ឃទូទៅ

ទី៣ : កន្ទោងបាយតារ ជាបញ្ចប់។

-ពិធីរាប់បាត្រត្រូវចាប់ផ្តើមពីផ្តិលតង្វាយព្រះរៀងរហូតមកដល់កន្ទោងបាយតារ

ពិធីរាប់បាត្រមិនមានកំណត់ថា ត្រូវរាប់៣វែកទេក្នុងបាត្រមួយៗ ។ បើគ្នាច្រើនរាប់តែមួយវែកបានហើយ បើគ្នាតិច គួរលៃល្មមព្រះសង្ឃឆាន់គ្រប់គ្រាន់។

-កន្ទោងបាយតារ

បូរាណាចារ្យលោកធ្វើកន្ទោងបាយតារ សម្រាប់ឧទ្ទិសដល់ប្រេត គេនិយមធ្វើកន្ទោងបាយតារពីស្លឹកចេក ឬ ក្រដាសអាលុយមីនីញ៉ូ (aluminium) ឬ យកចានគោមជំនួស ក៏បានដែរ។

បាយដាក់ក្នុងកន្ទោងបាយតារ ត្រូវចាត់ទុកដោយឡែកនៅក្បែរកន្ទោងនោះ គេមិនឲ្យយកបាយសម្រាប់ដាក់បាត្រព្រះសង្ឃ ទៅដាក់ទេ។

បូរាណគេនិយមយកដៃចិបបាយដាក់កន្ទោងបាយតារ ប៉ុន្តែបើយើងប្រើស្លាបព្រាក៏បានដែរ តែ កុំប្រឡំយកបាយសម្រាប់ដាក់បាត្រព្រះសង្ឃ ទៅដាក់ក្នុងកន្ទោងបាយតារ។

លុះចប់ពិធីរាប់បាត្រហើយ គេយកកន្ទោងបាយតារនោះទៅឲ្យគេដាក់ម្ហូបចំណីបន្តិចបន្តួច ពីលើបាយ ហើយយកមកឲ្យអ្នកដើមបុណ្យសម្រាប់ច្រួចទឹកនៅពេលសូត្រយំកិញ្ចិ....។ ចប់យំកិញ្ចិត្រូវឈប់ច្រួចទឹក។ អ្នកមិនមានកន្ទោងបាយតារ អាចច្រួចទឹកលើភាជនៈ ដូចជាចានជាដើមក៏បាន។

លុះសូត្រ យំកិញ្ចិ... ចប់ហើយ គេយកកន្ទោងនោះ ទៅដាក់នៅក្រៅផ្ទះ ដូចជាគៀនរបងជាដើម ព្រោះថា ពពួកប្រេត បើដាក់ ម្ហូបបាយទឹកក្នុងភាជនៈល្អឬ នៅកន្លែងល្អពេក នោះប្រេតមិនអាចបរិភោគបានទេ។ នេះ ហេតុមកពី ផលនៃកម្ម ដែលជាអកុសល របស់ខ្លួន បានសាងទុកនោះ ។

៧-ព្រះសង្ឃសូត្រធម៌បង្សុកូល អនុមោទនា,

៨-ពុទ្ធបរិស័ទផ្សាយបុណ្យកុសលដល់អ្នកដ៏មានគុណព្រមទាំងពួកញាតិនិង សព្វសត្វទូទៅ ដោយសូត្រធម៌យំកិញ្ចិ...ជាដើម ជាកិច្ចបញ្ចប់បុណ្យនៅពេលព្រឹក។ បើមានធម្មទេសនា លោកអាចារ្យជម្រាបដល់ពុទ្ធបរិស័ទថាមានធម្មទេសនា នៅ ម៉ោង១៣.០០ បន្ទាប់ពីពិសាចំណីអាហារ រួចស្រេច (៣),

៩-ព្រះសង្ឃ និមន្តឆាន់ភោជនាហារ ពីម៉ោង១១ ទៅដល់ ម៉ោង១២។ ពីថ្ងៃត្រង់ទៅ ព្រះសង្ឃពុំអាចឆាន់ចំណីអាហារបានទេ ក្រៅពីភេសជ្ជៈ .

១០-ជាមួយគ្នានោះពុទ្ធបរិស័ទក៏រៀបចំ ពិសាចំណីអាហារដែលអ្នកដើមបុណ្យ បានរៀបចំទុករួចស្រេចហើយ ក្នុងបរិយាកាស រីករាយ ជាមិត្តភាព ជាភាតរភាព ។

១១-បើមានកម្មវិធីសំដែងធម៌ទេសនា (ស្រេចលើអ្នកដើមបុណ្យ) ព្រះសង្ឃនឹងសម្តែង ធម៌ទេសនា នៅវាងម៉ោង ១៣.០០ ជាកិច្ចបង្ហើយបុណ្យដោយបរិបូរណ៍ ។

<u>សេចក្តីសង្កេត</u> : បុណ្យខ្លះអាចធ្វើនៅពេលរសៀលបាន ហើយចាប់ពីម៉ោង១៤.០០ទៅ ដូចជាបុណ្យផ្កា ជាដើម ហើយរបៀប នមស្សការព្រះរតនត្រ័យ សមាទានសីល និងនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត នៅដដែល តែបាលីវេរបុណ្យផ្កាខុសពីបាលីវេរកត្ត។ ក្រៅពីបុណ្យផ្កា បុណ្យដែលអាចធ្វើពេលរសៀលបានមាន សូត្រមន្តឡើងផ្ទះ អាពាហ៍ ពិពាហ៍ ឬ បង្សុកូល ជូនអ្នក ដែលទទួលអនិច្ចកម្មទៅហើយ។

---

(៣)-គួរតែមានធម្មទេសនា ដើម្បីជាឱកាសដល់ពុទ្ធបរិស័ទខ្លះ ដែលពុំសូវមានពេលមកស្តាប់ធម៌ ឬ សិក្សាពិចារណានូវធម៌ នៃព្រះពុទ្ធសាសនា។

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។